ព្រះរាជាណាចក្រកម្ពុជា - 100 -

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល
សំណុំរឿងព្រហ្មទណ្ឌ
លេខ : ២៨
ចុះថ្ងៃទី១៦ .០៥ ២០០២
សាលដីកា
លេខ : ០៤
ចុះថ្ងៃទី០៥ .០២ ២០០៣

តាងនាមប្រជារាស្ត្រខ្មែរ

# តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី០៥ខែកុម្ភៈឆ្នាំ ២០០៣

ដែលមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ :

១ - ឯកឧត្តម ឃឹម ប៉ុណ្ណ ប្រធាន

២ - លោក ឈឹម ស៊ីផល ចៅក្រម

៣ - លោក ខេវៀល មួន ចៅក្រម

៤ - លោក ប្រាក់ គីមសាន ចៅក្រម

៥ - លោក យស់ សូខឿន ចៅក្រមរបាយការណ៍

លោក ឃាង ស្រ៊ុន ក្រឡាបញ្ជី

តំណាងមហាអយ្យការ

លោក លោក សាយណារី ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាព្រហ្មទណ្ឌលេខ១៥៦ចុះថ្ងៃទី១៨ .០៧ ២០០១របស់សាលាឧទ្ធរណ៍និងសំណុំរឿងព្រហ្មទណ្ឌលេខ២៨ចុះថ្ងៃទី១៦ .០៥ ២០០២ របស់តុលាការកំពូល ។

- ជនជាប់ចោទឈ្មោះឃឹម ឃី "ចុងបណ្តឹងសាទុក្ខ" ភេទប្រុសអាយុ២៧ឆ្នាំនៅភូមិតាមខ្នង ឃុំផ្លូវទូក ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង មុខរបរនេសាទត្រី ប្រពន្ធឈ្មោះញ៉ិត យ៉ាន មានកូន០៣នាក់ ។ បច្ចុប្បន្ននៅក្នុងពន្ធនាគារខេត្ត ។

- ត្រូវចោទពីបទ :រំលោភសេពសន្ថវៈកាលពីថ្ងៃទី០២ .១១ .១៩៩៩ប្រព្រឹត្តនៅបឹងក្រឡាង ឃុំផ្លូវទូក ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង តាមមាត្រា៣៣នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ "ប្តឹងសាទុក្ខ"
- មេធាវី លោក ពេជ វិសាល

- ដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ ចាន់ ផល្លី ត្រូវជាបងស្រីរបស់ជនរងគ្រោះ ឈ្មោះ ចាន់ ថាវី កើតឆ្នាំ ១៩៨៤ នៅភូមិផ្សារលើ ឃុំ - ស្រុក - ខេត្ត កំពង់ឆ្នាំង ។

- មេធាវី គ្មាន

- តាមពាក្យបណ្តឹងចុះថ្ងៃទី១២ - ១១ - ១៩៩៩ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ចាន់ ផល្លី ប្តឹងពីឈ្មោះ ឃឹម ឃី និង ឈ្មោះ ចក់ បានរួមគំនិតគ្នា ចាប់រំលោភសេពសន្ថវៈលើ ប្អូនស្រីរបស់ខ្លួន ឈ្មោះ ចាន់ ថាវី ដោយប្អូនខ្លួន ទំរើបំរាស់តែមិនរួច ត្រូវឈ្មោះ ឃឹម ឃី ចាប់រំលោភ ២ ដង ក្នុងយប់ថ្ងៃទី ០២ - ១១ - ១៩៩៩ ។

- បានឃើញសេចក្តីសំរេច លើកលែងចោទប្រកាន់លេខ២៥១ចុះថ្ងៃទី២១ - ០២ - ២០០០

របស់ចៅក្រមស៊ើបអង្កេតតុលាការខេត្ត កំពង់ឆ្នាំង ដែលមានខ្លឹមសារដូចតទៅ :

១ - លើកលែងចោទប្រកាន់លើឈ្មោះយឹម ឈី ភេទ ប្រុស អាយុ២៧ ឆ្នាំ ជាតិខ្មែរ របររកស៊ីនេសាទត្រី កើតនៅភូមិតាមខ្លង ឃុំផ្លូវទូក ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ។ទីលំនៅ ភូមិតាមខ្លង ឪពុកឈ្មោះយឹម ញ៉ាប "ស"ម្តាយឈ្មោះ ទាំ- អូន "រ" ប្រពន្ធឈ្មោះហ៊ួត យ៉ាន មាន កូន ០៣ នាក់ ។

- ដាក់ចោទពីបទ ចាប់រំលោភសេពសន្ថវៈលើនារីភេទ ប្រព្រឹត្តនៅភូមិ បឹងក្រឡាង ឃុំផ្លូវទូក ស្រុកកំពង់លែង ខេត្ត កំពង់ឆ្នាំង កាលពីថ្ងៃទី០២ - ១១ - ១៩៩៨ និង សំរេចអោយដោះលែងឈ្មោះនេះចេញពីបន្ទីរឃុំឃាំងជាបន្ទាន់ បើជននោះមិនត្រូវឃុំខ្លួនពីបទ ល្មើសអ្វីផ្សេងទៀតទេ ។

- បានឃើញបណ្តឹងឧទ្ធរណ៍លេខ០៥ចុះថ្ងៃទី ២៥ - ០២ - ២០០០របស់លោក ព្រះរាជ អាជ្ញារងតុលាការខេត្ត កំពង់ឆ្នាំង តវ៉ាពីដីកាលើកលែងចោទប្រកាន់លេខ២៥១ ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០០០ របស់តុលាការខេត្ត កំពង់ឆ្នាំ លើសេចក្តីសំរេចទាំងមូល ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់មហាអយ្យការអមសាលាឧទ្ធរណ៍សន្និដ្ឋាននាពេលសវនាការថា:

១ - បដិសេធបណ្តឹងឧទ្ធរណ៍របស់លោកម៉ក់ ហ៊ាន ចុះថ្ងៃទី២៥ - ០២ - ២០០០ ចោល ជាអាសារបង់ ។

២ - មិនទទួលជំនុំជំរះដល់អង្គសេចក្តី ។

- បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ១៥៦ ចុះថ្ងៃទី ១៨ - ០៧ - ២០០១ របស់ សាលាឧទ្ធរណ៍ដែលមានសេចក្តីសំរេចដូចតទៅ :

១ - បដិសេធបណ្តឹងឧទ្ធរណ៍លេខ ០៥ ចុះថ្ងៃទី២៥ - ០២ - ២០០០ របស់លោក ព្រះ រាជអាជ្ញារងតុលាការខេត្ត កំពង់ឆ្នាំង ដោយខុសនឹងទំរង់ច្បាប់ ។

២ - មិនទទួលជំនុំជំរះនូវសំណុំរឿងព្រហ្មទណ្ឌលេខ ៥៥ ចុះថ្ងៃទី២៥ ខែ កុម្ភៈឆ្នាំ២០០០ របស់ សាលាឧទ្ធរណ៍ ។

- បានឃើញបណ្តឹងសាទុក្ខលេខ ៦៧ ចុះថ្ងៃទី១៣ - ០៨ - ២០០១ របស់ អគ្គព្រះ រាជអាជ្ញាសាលាឧទ្ធរណ៍ តវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ ១៥៦ ចុះថ្ងៃទី ១៨ - ០៧ - ២០០១ របស់ សាលាឧទ្ធរណ៍ ត្រង់ចំណុចទី១ ២ ៣ នៃសាលដីកា ។

- បានឃើញសារណាក្នុងបណ្តឹងសាទុក្ខចុះថ្ងៃទី១៦ -១០ -២០០១ របស់អគ្គព្រះរាជ អាជ្ញាសាលាឧទ្ធរណ៍ .

- បានឃើញសារណាតបចុះថ្ងៃទី០៤ - ០៦ - ២០០២ របស់ឈ្មោះយឹម ឈី .

- បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍.

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលថាៈមាន ពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះយឹម ឈី ប្រាកដមែន ហើយសុំតម្កល់សាលដីកាសាលាឧទ្ធរណ៍ទុកជាបានការ។

- បានស្តាប់ក្រឡាបញ្ជីអានបណ្តឹងសាទុក្ខរបស់អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ .

- បានស្តាប់ក្រឡាបញ្ជីអានសារណារបស់អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍.

- បានស្តាប់ក្រឡាបញ្ជីអានសារណាតបរបស់ជនជាប់ចោទឈ្មោះ ឈឹម ណី .

- បានស្តាប់មេធាវីលោក ពេជ វិសាល ការពារអោយជនជាប់ចោទបានលើកនាពេល សវនាការថា:ចំពោះរឿងនេះ ឃើញថាការប្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាអាចហួសពេលកំណត់ច្បាប់ ។ ហើយការបញ្ជូនសំណុំរឿងមួលទៅព្រះរាជអាជ្ញាមានរយៈពេលទុកបីថ្ងៃណោះ ដូច្នេះមិនអាចសន្និដ្ឋានថា បន្ទាន់ភ្លាមនោះទេ ម្យ៉ាងវិញទៀតបើពិនិត្យលើករណីឃុំខ្លួនមានរយៈពេលពីរឆ្នាំហើយ ការឃុំខ្លួននៅក្នុងច្បាប់បើគ្មានភស្តុតាង ឬ សំរេចអំពីការផ្តន្ទាទោសទេនោះ គប្បីដោះលែងអោយនៅក្រៅឃុំជាបណ្តោះអាសន្ន ដែលពួកថ្ងៃនេះហួសពីការស៊ើបអង្កេតរបស់តុលាការ ហេតុនេះសូមក្រុមប្រឹក្សាជំនុំជំរះមេត្តាតម្កល់សាលដីកាសាលាឧទ្ធរណ៍ ។

- បានស្តាប់សេចក្តីសន្និដ្ឋាន បន្ថែមរបស់តំណាងមហាអយ្យការថា: ពុំមានអ្វីបន្ថែមទៀតទេ សូមរក្សា ការសន្និដ្ឋានរបស់ខ្លួននាពេលសវនាការទុកជាបានការដដែល .

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍ .

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ.

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍សារណា របស់ជនជាប់ចោទ និង សេចក្តីសន្និដ្ឋានការពាររបស់មេធាវីជនជាប់ចោទ .

- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ .

តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ៦៦ ចុះថ្ងៃទី១៣-៥-២០០១ របស់អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ធ្វើទៀងក្នុងកំណត់ច្បាប់តុលាការកំពូល អាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថាការដែលសាលាឧទ្ធរណ៍សំរេចមិនទទួលជំនុំជំរះសំណុំរឿងព្រហ្មទណ្ឌលេខ៩៥ ចុះថ្ងៃទី២៥ ២ ២០០០ របស់សាលាឧទ្ធរណ៍ដោយសំអាងថាបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាអមតុលាការខេត្តកំពង់ឆ្នាំងធ្វើទៀងផុតកំណត់ច្បាប់នោះជាមិនត្រឹមត្រូវទេ ពីព្រោះចៅក្រមស៊ើបអង្កេតបានចេញដីកាលើកលែងចោទប្រកាន់នៅថ្ងៃទី២១ ២ ២០០០ រួចបញ្ជូនទៅព្រះរាជអាជ្ញាពិនិត្យ ព្រះរាជអាជ្ញាក៏ចេញដីកាបង្គាប់អោយស៊ើបសួរបន្ថែមចុះថ្ងៃទី២២-២-២០០០ ចៅក្រមស៊ើបអង្កេតបានឆ្លើយតបនិងដីកាបង្គាប់ឱ្យស៊ើបសួរបន្ថែមនេះនៅថ្ងៃទី២៣-២-២០០០ ព្រះរាជអាជ្ញាចារលើដីកាលើកលែងចោទប្រកាន់និងប្តឹងតវ៉ានៅថ្ងៃទី២៥ ២-២០០០ ដូចនេះបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាអមតុលាការខេត្តកំពង់ឆ្នាំងស្ថិតនៅក្នុងកំណត់ច្បាប់នៅឡើយ ។

- យល់ឃើញថាការដែលចៅក្រមស៊ើបអង្កេតបញ្ជូនរឿងទៅពិនិត្យមុននៅថ្ងៃទី ២១-២-២០០០ ជាមួយគ្នានឹងដីកាលើកលែងចោទប្រកាន់ ជាការរំលោភលើមាត្រា ៨៥ នៃ ច្បាប់ ស្តីពីនីតិវិធីព្រហ្មទណ្ឌ និង ជាការបំពានសិទ្ធិអយ្យការក្នុងរឿងក្តីនេះ ។

.....៤ ....

- យល់ឃើញថា ជនជាប់ចោទបានត្រូវឃុំឃាំងជាបណ្ដោះអាសន្នតាំងពីថ្ងៃទី ២៨ ខែមករា ឆ្នាំ២០០០ មកដែលសប្ដីសាលាឧទ្ធរណ៍ពិចារណា ។

- យល់ឃើញថា ជនជាប់ចោទបានធ្វើសារណាជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានចូលរួមក្នុងពេលសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះកំបាំងមុខជនជាប់ចោទ ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថាសាលដីកាព្រហ្មទណ្ឌលេខ១៥៦ចុះថ្ងៃទី១៨ - ៧ - ២០០១ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្ដីមកនេះ មានការខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្ដីចំពោះមុខមេធាវីជនជាប់ចោទ កំបាំងមុខជនជាប់ចោទនិង ដើមបណ្ដឹងរដ្ឋប្បវេណី ប៉ុន្តែចាត់ទុកជាចំពោះមុខ

១ - ទទួលបណ្ដឹងសាទុក្ខលេខ៦៦ ចុះថ្ងៃទី១៣ - ៨ - ២០០១ របស់អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២ - ទុកជាមោឃៈសាលដីកាព្រហ្មទណ្ឌលេខ ១៥៦ ចុះថ្ងៃទី១៨-៧-២០០១ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣ - បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ១២៨ចុះថ្ងៃទី១៦ - ០៥ - ២០០២របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះឡើងវិញ ។

៤ - សាលដីកានេះប្រកាសតាមសវនាការជាសាធារណៈនៅថ្ងៃទី០៥ ខែ កុម្ភៈ ឆ្នាំ ២០០៣ ។